# អន្តរកាលៈ ការចាប់ផ្តើមចូលរៀនប្រកបដោយវិជ្ជមាន

គោលការណ៍ណែនាំដើម្បីជួយគ្រួសារបំពេញសេចក្តីថ្លែងការណ៍អំពីអន្តរកាលរៀនសូត្រ និងការអភិវឌ្ឍន៍

## ហេតុអ្វីការចាប់ផ្តើមចូលរៀនប្រកបដោយវិជ្ជមានសំខាន់?

ការចាប់ផ្តើមចូលរៀនប្រកបដោយវិជ្ជមាន អាចជួយកូនរបស់អ្នករៀនបានប្រសើរជាងមុន ហើយមានអារម្មណ៍សប្បាយរីករាយនៅពេលផ្លាស់ប្តូរពីមត្តេយ្យសាលា ទៅសាលារៀន និងទៅការរៀនសូត្រនាពេលអនាគតរបស់ពួកគេ។ អន្តរកាលវិជ្ជមានក៏ជួយដល់ការបន្តនៃការរៀនសូត្រ និងការអភិវឌ្ឍន៍របស់កូនអ្នកផងដែរ តាមរយៈការកសាងបទពិសោធន៍ពីមុន និងបច្ចុប្បន្នរបស់កូនអ្នក ដើម្បីជួយពួកគេឱ្យមានអារម្មណ៍មានសុវត្ថិភាព ទំនុកចិត្ត និងមានទំនាក់ទំនង។ ការចាប់ផ្តើមចូលរៀនប្រកបដោយវិជ្ជមានក៏អាចជួយពួកគេឱ្យមានភាពធន់ទ្រាំថែមទៀត។

## តើអ្វីទៅជាសេចក្តីថ្លែងការណ៍អំពីអន្តរកាលរៀនសូត្រ និងការអភិវឌ្ឍន៍?

សេវាកម្មកុមារតូច សាលារៀន សេវាកម្មថែទាំក្រៅម៉ោងសាលា (OSHC) និងក្រុមគ្រួសារធ្វើការរួមគ្នាដើម្បីគាំទ្រដល់ការរៀនសូត្រ និងសុខុមាលភាពរបស់កុមារ។ ពួកគេចែករំលែកព័ត៌មានដោយប្រើសេចក្តីថ្លែងការណ៍អំពីអន្តរកាលរៀនសូត្រ និងការអភិវឌ្ឍន៍(TLDS)។ សេចក្តីថ្លែងការណ៍នេះត្រូវបានសរសេរដោយសេវាកម្មកុមារតូច សម្រាប់កុមារគ្រប់រូបនៅពេលពួកគេទៅសាលារៀន។

TLDS ចែករំលែកព័ត៌មានអំពីការរៀនសូត្រ ការអភិវឌ្ឍន៍ និងសុខុមាលភាពរបស់កូនអ្នក រវាងសេវាកម្មកុមារតូច និងសាលារៀន។ TLDS ផ្តល់នូវការមើលឃើញភ្លាមៗអំពីចំណង់ចំណូលចិត្ត ជំនាញ និងសមត្ថភាពរបស់កូនអ្នក ហើយកំណត់បង្ហាញវិធីសាស្ត្របុគ្គល និងយុទ្ធសាស្ត្របង្រៀនដើម្បីគាំទ្រកូនរបស់អ្នក។

TLDS អាចជួយអ្នកឱ្យយល់ដឹង និងគាំទ្រការរៀនសូត្ររបស់កូនអ្នក នៅពេលពួកគេចាប់ផ្តើមទៅរៀននៅសាលា។ ព័ត៌មាននៅក្នុង TLDS ជួយគ្រូថ្នាក់មូលដ្ឋានឱ្យស្គាល់កូនរបស់អ្នក និងរៀបចំកម្មវិធីបង្រៀនសមរម្យនានា។ ប្រសិនបើកូនរបស់អ្នកនឹងស្ថិតក្នុង OSHC នោះ TLDS ជួយរៀបចំផែនការសម្រាប់ពេលវេលារបស់ពួកគេនៅទីនោះផងដែរ។

TLDS មានព័ត៌មានលម្អិតផ្ទាល់ខ្លួនមួយចំនួន រួមមានឈ្មោះ ខួបកំណើត និងរូបថតរបស់កូនអ្នក ព្រមទាំងឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នកផងដែរ។ វាក៏អាចមានឈ្មោះ និងព័ត៌មានលម្អិតនៃទំនាក់ទំនងរបស់អ្នកជំនាញកុមារភាពផ្សេងទៀត ដែលបានគាំទ្រកូនរបស់អ្នក។

ការរួមចំណែកដល់ TLDS របស់កូនអ្នកគឺជាអន្តរកាលមួយទៅកាន់សកម្មភាពសាលាដែលអ្នក និងកូនរបស់អ្នកអាចចូលរួមជាមួយគ្នា មុនពេលសាលារៀនចាប់ផ្តើម។

## តើខ្ញុំចូលប្រើប្រាស់ TLDS របស់កូនខ្ញុំដោយរបៀបណា?

សេវាកម្មកុមារតូចរបស់កូនអ្នក នឹងផ្តល់ឱ្យអ្នកនូវតំណភ្ជាប់មួយទៅកាន់ឧបករណ៍ TLDS អនឡាញ។ TLDS អនឡាញ គឺជាមធ្យោបាយដ៏ល្អបំផុតដើម្បីបំពេញ TLDS ។

ប្រសិនបើអ្នកមិនអាចប្រើប្រាស់ឧបករណ៍អនឡាញបានទេ អ្នកអាចស្នើសុំច្បាប់ចម្លងជាក្រដាសជំនួសវិញ។

## តើខ្ញុំត្រូវបំពេញ TLDS ផ្នែកមួយណា?

*ផ្នែកទី 1* និង *1.1* ត្រូវបំពេញដោយអ្នកអប់រំកុមារតូចរបស់កូនអ្នក។

*ផ្នែកទី 1.2* អាចត្រូវបានបំពេញដោយអ្នកអប់រំកុមារតូចរបស់កូនអ្នក ប្រសិនបើកូនរបស់អ្នកមានការអភិវឌ្ឍន៍យឺតយ៉ាវ ឬពិការភាព។ អ្នកជំនាញផ្សេងទៀតដែលជួយកូនរបស់អ្នក ក៏អាចបន្ថែមទៅក្នុងផ្នែកនេះផងដែរ។

*ផ្នែកទី 2: កុមារ* ត្រូវបំពេញដោយកូនរបស់អ្នកជាមួយមនុស្សពេញវ័យដែលពួកគេស្គាល់ច្បាស់។ នេះអាចជាអ្នក ឬអ្នកអប់រំកុមារតូចរបស់ពួកគេ។

*ផ្នែកទី 3៖ គ្រួសារ* គឺសម្រាប់អ្នកបំពេញ។ មតិយោបល់របស់អ្នកមានសារៈសំខាន់។ ផ្នែកនេះមានសំណួរនានាដើម្បីជួយអ្នកចែករំលែកចំណាប់អារម្មណ៍របស់កូនអ្នក ក៏ដូចជាគំនិត និងក្តីសង្ឃឹមរបស់អ្នក ចំពោះកូនរបស់អ្នកនៅសាលារៀន។ ការឆ្លើយសំណួរទាំងនេះអាចជួយគ្រូបង្រៀន និងបុគ្គលិក OSHC (ប្រសិនបើមាន) ដើម្បីឆ្លើយតប និងយល់ដឹងពីកូនរបស់អ្នក ដែលនឹងគាំទ្រដល់ការរៀនសូត្រ និងការអភិវឌ្ឍន៍របស់ពួកគេ។

## តើមានអ្វីកើតឡើងបន្ទាប់ពីបានបំពេញ TLDS?

បន្ទាប់ពីបំពេញ TLDS អ្នកអប់រំកុមារតូចរបស់អ្នក នឹងផ្តល់ឱ្យអ្នកនូវច្បាប់ចម្លងដែលបានបំពេញរួចមួយច្បាប់។

អ្នកអប់រំកុមារតូចរបស់អ្នកក៏នឹងចែករំលែក TLDS ដែលបានបំពេញរួច ជាមួយសាលារៀន និងសេវាកម្ម OSHC របស់កូនអ្នកផងដែរ (ប្រសិនបើមាន)។

ប្រសិនបើអ្នកមិនប្រាកដពីសាលាមួយណាដែលកូនរបស់អ្នកនឹងចូលរៀនទេ អ្នកអប់រំកុមារតូចរបស់អ្នក នឹងផ្តល់ឱ្យអ្នកនូវច្បាប់ចម្លងទីពីរនៃ TLDS។ អ្នកអាចផ្តល់ឱ្យសាលារៀននូវច្បាប់ចម្លងទីពីរនៃ TLDSនេះ នៅពេលអ្នកចុះឈ្មោះកូនរបស់អ្នក។

ប្រសិនបើអ្នកមិនបំពេញ *ផ្នែកទី 3៖ គ្រួសារ* ទេ អ្នកអប់រំកុមារតូចរបស់កូនអ្នក នឹងនៅតែចែករំលែកផ្នែកដែលបានបំពេញរួចផ្សេងទៀតជាមួយសាលារៀន និងសេវាកម្ម OSHC (ប្រសិនបើមាន) ហើយផ្តល់ឱ្យអ្នកនូវច្បាប់ចម្លងដែលត្រូវបានចែករំលែកនោះ។

ការស្រាវជ្រាវ និងមតិកែលម្អពីសាលារៀនបានបង្ហាញថា ការចែករំលែកព័ត៌មាននេះ គាំទ្រដល់អន្តរកាលទៅសាលារៀនប្រកបដោយជោគជ័យ។ ប្រសិនបើអ្នកមិនចង់ចែករំលែក TLDS ជាមួយសាលារៀនរបស់កូនអ្នកទេ សូមពិភាក្សារឿងនេះជាមួយអ្នកអប់រំកុមារតូចរបស់កូនអ្នក។

ព័ត៌មានសមស្រប និងប្រកបដោយសុវត្ថិភាពជួយឱ្យអ្នកជំនាញផ្នែកអប់រំ និងថែទាំរដ្ឋវិចថូរៀមានចំណេះដឹង និងព័ត៌មានចាំបាច់ ដើម្បីធានាបាននូវសុខុមាលភាព និងសុវត្ថិភាពកុមារ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលhttps://www.vic.gov.au/information-sharing-schemes-and-the-maram-framework

## សម្រាប់ព័ត៌មានបន្ថែម

ដើម្បីស្វែងយល់បន្ថែម អ្នកអាចចូលទៅកាន់គេហទំព័រ www.vic.gov.au/transition-school-resources-families

ព័ត៌មាននេះក៏មានជាភាសាសហគមន៍មួយចំនួនផងដែរនៅតំណដូចគ្នា៖ www.vic.gov.au/transition-school-resources-families